# ក

## សេចក្តីកែតម្រូវ

***ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១១៥ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ និង ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក ដែលយើងខ្ញុំបានចុះផ្សាយនៅក្នុងរាជកិច្ច ឆ្នាំទី ៣ លេខ ១០ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៣ មានការខុសពីលក្ខណៈដើម ដោយកំហុសបច្ចេកទេស។

អាស្រ័យហេតុនេះយើងខ្ញុំសូមចុះផ្សាយទាំងស្រុងនូវព្រះរាជក្រឹត្យទាំង ២ នេះឡើងវិញ។

*សូមអភ័យទោស...សូមអរគុណ..!*

## មាតិកា

### I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១១-៣-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១១៥ ស្តីពី ការកំណត់ រមណីយដ្ឋានប្រាសាទព្រះវិហារ ២៩៦១

១១-៣-២០០៣ - ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១១៦ ស្តីពីការកំណត់ រមណីយដ្ឋានសំបូរព្រៃគុក ២៩៦៧

១៩-៧-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៤១ ស្តីពីការតែងតាំងៈ

- លោក **ជួន កុល**, លោក **ឡាយ ស៊ា** ជា **ឧកញ៉ា** ២៩៧៣


### II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


០១-៩-២០០៣ -អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៤ ២៩៧៤

០៨-៩-២០០៣ -អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពីការគ្រប់គ្រងការអនុវត្តន៏ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល ២៩៧៦

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៩

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៦៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨០

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨១

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨២

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៦៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៣

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៤

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៥

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៦

០១-៩-២០០៣ -អនុក្រឹត្យលេខ ៧៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៧

| | | |
|---|---|---|
| ០១-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៨៨ |
| ០១-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២៩៨៩ |
| ០២-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៩៩០ |
| ០២-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩២ |
| ០២-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៣ |
| ០២-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៤ |
| ០២-៩-២០០៣ | -អនុក្រឹត្យលេខ ៧៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៥ |
| ០២-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៦ |
| ០៤-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៧ |
| ០៤-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៨ |
| ០៤-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៩៩ |
| ០៤-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៣០០០ |
| ០៤-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០០១ |
| ០៤-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៦ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ | ៣០០២ |
| ០៥-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០០៤ |
| ០៥-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០០៦ |
| ០៥-៩-២០០៣ | -អនុក្រឹត្យលេខ ៧៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០០៧ |
| ០៥-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០០៩ |
| ០៥-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០១០ |
| ០៥-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០១១ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ | ៣០១២ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០១៣ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០១៤ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៣០១៦ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០៤៥ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០៤៦ |
| ០៨-៩-២០០៣ | -អនុក្រឹត្យលេខ ៧៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៣០៤៧ |

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១១៥

## ស្តីពី

## ការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

*****

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទព្រះវិហារ ជារមណីយដ្ឋានការពារ ស្ថិតនៅលើភ្នំព្រះវិហារនៃជួរភ្នំដងរែក ក្នុងភូមិសាឯម ( អតីតភូមិស្វាយជ្រុំ ) ឃុំកន្ទួត ស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋានការពារនេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបូរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកកំរិតតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

តំរូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទព្រះវិហារ ត្រូវចាត់ជា ៣ ( បី ) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក - **តំបន់ទី ១ :** ជាតំបន់រមណីយដ្ឋានប្រាសាទ ហៅថា **តំបន់ស្នូល** កំណត់យកតួភ្នំទាំងមូល

គិតចាប់ពីកំពូលភ្នំ នៃប្រាសាទព្រះវិហារចុះក្រោម រហូតដល់ខ្សែរយៈកំពស់ ៥០០ម៉ែត្រ កំណត់ដោយចំណុច ដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយដូចតទៅ ៖

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| 1 | $14^0$ | 23’ | 19” | $104^0$ | 40’ | 54” |
| 2 | 14 | 23 | 27 | 104 | 40 | 46 |
| 3 | 14 | 23 | 37 | 104 | 40 | 35 |
| 4 | 14 | 23 | 30 | 104 | 41 | 14 |
| 5 | 14 | 23 | 42 | 104 | 41 | 21 |
| 6 | 14 | 23 | 59 | 104 | 41 | 31 |
| 7 | 14 | 25 | 15 | 104 | 41 | 04 |
| 8 | 14 | 23 | 48 | 104 | 40 | 37 |
| 9 | 14 | 23 | 53 | 104 | 40 | 43 |

និង ខ្សែបន្ទាត់ព្រំដែនកម្ពុជា - ថៃ ។

តំបន់នេះ ជាតំបន់មានប្រាសាទព្រះវិហារ សំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

ខ - **តំបន់ទី ២ :** ជាតំបន់អភិរក្សទេសភាពវប្បធម៌ បរិស្ថានធម្មជាតិ ហៅថា **តំបន់ទ្រនាប់** កំណត់យកផ្ទៃដីចន្លោះបរិវេណនៃតំបន់ស្នូល និង ខ្សែបន្ទាត់ដែលមាន ៖

- ចំណុចប្រសព្វមុខរវាងខ្សែបន្ទាត់រង្វង់ កាំប្រវែង ៣ គ.ម ចំណុចផ្ចិត **E:** រយៈទទឹង **$14^0$ 23’ 39”**; រយៈបណ្តោយ **$104^0$ 41’ 02”** នៅចំអ័ក្សត្រង់កាំជណ្តើរក្រោមបំផុតនៃប្រាសាទព្រះវិហារ និងខ្សែបន្ទាត់ព្រំដែនកម្ពុជា - ថៃ ហើយនិងអ័ក្សផ្លូវចេញទៅច្រក **តាថាវ** តាមបណ្តោយផ្លូវទៅស្រុកអន្លង់វែងត្រង់ចំណុច ៖

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| **A** | $14^0$ | 24’ | 22” | $104^0$ | 42’ | 33” |
| **B** | 14 | 22 | 32 | 104 | 42 | 33 |
| **C** | 14 | 22 | 47 | 104 | 39 | 48 |
| **D** | 14 | 23 | 18 | 104 | 40 | 07 |
| **T** | 14 | 23 | 26 | 104 | 41 | 59 |

លើអ័ក្សផ្លូវឡើងទៅចង្កេះភ្នំប្រាសាទព្រះវិហារ រហូតដល់ ខ្សែរយៈកំពស់ ៥០០ម៉ែត្រ ។

តំបន់នេះសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារ ទប់ស្កាត់នឹងការប្រើប្រាស់ដីធ្លី នឹងការអភិវឌ្ឍមិនសមស្រប ។

គ - **តំបន់ទី ៣ :** ជាតំបន់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថា **តំបន់រណប** ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះស្ថិតពីខ្សែអ័ក្សខាងក្រៅរបស់តំបន់ទ្រនាប់ចម្ងាយ ១.៥០០ម៉ែត្រ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចិរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង គិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជា ពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការ ទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសអោយប្រើ ដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និង ការពាររមណីយដ្ឋានការពារប្រាសាទព្រះវិហារ ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់និមួយៗ នៃរមណីយដ្ឋានការពារប្រាសាទព្រះវិហារ អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាពដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកត.០៣.០៣.១២៣ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ៩៥ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី តាន់**




ផែនទីកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២១៥

ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០៣

ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

មាត្រដ្ឋាន 1:50000

សញ្ញាសំគាល់

| | |
|---|---|
| ━━━ | ផ្លូវសាងសង់ថ្មី |
| ━━━ | ផ្លូវចាស់នៅលើផែនទី |
| ++++ | ព្រំប្រទល់ប្រទេស |
| ━━━ | ខ្សែរយៈកំពស់៥០០ម. |
| ─── | ខ្សែពគ.ម ពីចំណុចកាំទី១ នៃជណ្តើរប្រាសាទ |
| ------- | ខ្សែព្រំប្រទល់តំបន់ទ្រនាប់ |

| ចំណុច | រយៈទទឹង | រយៈបណ្តោយ |
|---|---|---|
| -តំបន់ស្នូល | | |
| 1 | 14°23'19'' | 104°40'54'' |
| 2 | 14 23 27 | 104 40 46 |
| 3 | 14 23 37 | 104 40 35 |
| 4 | 14 23 30 | 104 41 14 |
| 5 | 14 23 42 | 104 41 21 |
| 6 | 14 23 59 | 104 41 31 |
| 7 | 14 25 15 | 104 41 04 |
| 8 | 14 23 48 | 104 40 37 |
| 9 | 14 23 53 | 104 40 43 |
| -តំបន់ទ្រនាប់ | | |
| A | 14 24 22 | 104 42 33 |
| B | 14 22 32 | 104 42 33 |
| C | 14 22 47 | 104 39 48 |
| D | 14 23 18 | 104 40 07 |
| T | 14 23 26 | 104 41 59 |
| -ចំណុចផ្ចិតរង្វង់មានកាំស្មើពគ.ម. | | |
| E | 14 23 39 | 104 41 02 |

ប្រភពផែនទី :

-ផែនទី ដងរែក របស់គណៈកម្មការកំណត់ព្រំដែនឥណ្ឌូចិន.សៀម ខ្នាត ១: ២០០០០០

-ទិន្នន័យវាស់វែងដោយ GPS ឆ្នាំ២០០២

-រូបភាពពីផ្កាយរណប SPOT ឆ្នាំ១៩៩៩

រៀបចំដោយនាយកដ្ឋានភូមិសាស្ត្រ.១២.២០០២.

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១១៦

## ស្តីពី

## ការកំណត់រមណីយដ្ឋានសំបូរព្រៃគុក

*****

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង គ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

- បានទទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ជារមណីយដ្ឋានការពារ ជាអតីតរាជធានីខ្មែរ ឈ្មោះថា ឥសានបុរៈ ក្នុងសតវត្សទី ៦-៧ ស្ថិតក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបូរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកកំរិតតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍន៍តំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង ។

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍន៍រមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក ត្រូវចាត់ជា ៣ (បី)តំបន់ ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

១- **តំបន់ស្នូល** : ជាតំបន់ឧទ្យានប្រាសាទតូច-ធំ រួមទាំងសម្បត្តិវប្បធម៌ បូរាណវិទ្យា ព្រមទាំងវត្ថុតាងជាច្រើនទៀត ដែលមានរូបរាងនៅលើដី ឬកប់ក្នុងដី កំពុងស្រាវជ្រាវ ឬ ពុំទាន់ស្រាវជ្រាវ

រកឃើញ ដោយអ្នកបុរាណវិទ្យា ។ តំបន់នេះ **ហៅថា តំបន់ស្នូល** មានផ្ទៃក្រឡាសរុប ៣៨១.១១ហិកតា ។

តំបន់ស្នូលនេះ រួមមានតំបន់ ៣ ( បី ) : តំបន់ **ក** តំបន់ **ខ** តំបន់ **គ** ។

តំបន់ស្នូលត្រូវបានកំណត់ដូចខាងក្រោមនេះ :

តំបន់ ក : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$A_1$ ( 504939 ; 1423496 ) , $B_1$ ( 504521 ; 1423004 )
$C_1$ ( 504210 ; 1422372 ) , $D_1$ ( 504110 ; 1421913 )
$E_1$ ( 504262 ; 1421680 ) , $F_1$ ( 504580 ; 1421665 )
$G_1$ ( 504536 ; 1421428 ) , $H_1$ ( 504380 ; 1421102 )
$I_1$ ( 504391 ; 1420751 ) , $J_1$ ( 504462 ; 1420736 )
$K_1$ ( 504680 ; 1421187 ) , $L_1$ ( 504773 ; 1421665 )
$M_1$ ( 505094 ; 1421665 ) , $N_1$ ( 505224 ; 1421950 )
$T_1$ ( 506889 ; 1422109 ) , $S_1$ ( 506575 ; 1422575 )
$P_1$ ( 505365 ; 1422549 ) , $Q_1$ ( 505513 ; 1423064 )
$R_1$ ( 505376 ; 1423437 )

តំបន់ ខ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$A_2$ ( 503211 ; 1425262 ) , $B_2$ ( 502904 ; 1424858 )
$C_2$ ( 503081 ; 1424185 ) , $D_2$ ( 504458 ; 1424288 )
$E_2$ ( 504613 ; 1425289 )

តំបន់ គ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$U_3$ ( 502552 ; 1421073 ) , $V_3$ ( 502045 ; 1420962 )
$W_3$ ( 501557 ; 1423004 ) , $Z_3$ ( 503577 ; 1423256 )

តំបន់ **ក ខ គ** ជាតំបន់មានប្រាសាទសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

២- **តំបន់ទ្រនាប់ :** ជាតំបន់ឧទ្យានបុរាណវត្ថុ ដែលមានបន្សល់ទុកនូវដានស្នាកស្នាម ឬ កប់ក្នុងដី រាក់ ឬជ្រៅ ពុំទាន់រុករកឃើញដោយអ្នកបុរាណវិទ្យា នៅតាមទីវាល ផ្ទៃដី ឬ ក្នុងភូមិ ឃុំ ក្រោមផ្ទះប្រជាពលរដ្ឋជាដើម ។ តំបន់នេះ **ហៅថាតំបន់ទ្រនាប់** មានផ្ទៃក្រឡា ២៩៨២.៤៥ហិកតា ។

តំបន់នេះស្ថិតនៅក្រៅបរិវេណនៃតំបន់ **ក** តំបន់ **ខ** និង តំបន់ **គ** នៃតំបន់ស្នូល ហើយស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

A ( 502721 ; 1426711 ) , B ( 501633 ; 1425998 )
C ( 500537 ; 1423348 ) , D ( 501733 ; 1418978 )
E ( 504456 ; 1420172 ) , F ( 505480 ; 1420622 )
G ( 505567 ; 1421717 ) , H ( 508911 ; 1421701 )
I ( 508909 ; 1422487 ) , J ( 505583 ; 1424066 )

K ( 505604 ; 1425246 )

តំបន់នេះសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារ ទប់ស្កាត់និងការប្រើប្រាស់ដីធ្លី និង ការអភិវឌ្ឍនមិនសមស្រប ។

៣- **តំបន់រណប :** ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថាតំបន់រណប ដោយរក្សាជីវភាព មុខរបរ អាជីវកម្ម តាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការចំណុច A B C D E F G H I J K ចម្ងាយ ១.៥០០ម៉ែត្រ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចិរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥ ..**

ការអភិរក្សរាល់តំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅ ចំណាត់ថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង គិតនៃសារៈសំខាន់ដោយឡែកៗ ទាំងខាង បូរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុង តំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦ ..**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការ ទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និង ការពារ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកក្នុង បណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧ ..**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក អាចពិនិត្យ ឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផល នៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាព

ជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនិងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩ .-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមិនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នស/រកត.០៣០៣.១៧៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ៩៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ តាន់**



# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៤១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

តែងតាំង

លោក ជួន ភ្វល

លោក ឡាយ ស៊ា

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣៤៤-០៣-០៧.២៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៣

លេខៈ ៧២០ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទីៈ ០៣ ខែ កញ្ញា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

តាន់

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦២ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៤

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ លេខ ១៦០/២០០៣/គ.ប.ជ.អ ចុះថ្ងៃទី ០១ សីហាឆ្នាំ ២០០៣ ។

## សម្រេច

<u>មាត្រា១</u> : អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សម្រាកការងារប្រចាំឆ្នាំ ២០០៤ តាមប្រតិទិនដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៥ | កុម្ភៈ | ទិវាបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី១៣-១៤-១៥ | មេសា | ទិវាចូលឆ្នាំខ្មែរប្រពៃណីជាតិ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

| | | | |
|---|---|---|---|
| - ថ្ងៃទី០៣ | ឧសភា | ទិវាបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៧ | ឧសភា | ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០១ | មិថុនា | ទិវាកុមារអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេច ព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១២-១៣-១៤ | តុលា | បុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី២៣ | តុលា | ទិវាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី៣០-៣១តុលា និង ០១វិច្ឆិកា | | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី០៩ | វិច្ឆិកា | ទិវាបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី២៥-២៦-២៧ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែនិងអកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា២:** ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍( សៅរ៍ ឬ អាទិត្យ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំងពីរ ថ្ងៃជាប់គ្នា គឺ ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់តែ ០១ ថ្ងៃប៉ុណ្ណោះ ។

**មាត្រា៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល

*******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យទាំងឡាយ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរាជការ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៣ ។

# សំ រេ ច

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ទៅតាមកំរិតសញ្ញាប័ត្រ និងមុខតំណែងរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ២.-

ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិតាមកំរិតសញ្ញាប័ត្រមិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែករណីដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។

មាត្រា ៣.-

ការផ្លាស់ប្តូរក្របខ័ណ្ឌទៅតាមកំរិតសញ្ញាប័ត្រធ្វើទៅបាន តែតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងរបស់ក្រសួងស្ថាប័ន ដែលគ្រប់គ្រងក្របខ័ណ្ឌនោះ ។

ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ទៅតាមកំរិតសញ្ញាប័ត្រក៏អាចធ្វើទៅបានដែរចំពោះករណីដែលមន្ត្រីរាជការនោះ ធ្លាប់ទទួលបៀវត្សទៅតាមកំរិតសញ្ញាប័ត្រ ហើយដែលត្រូវតែងតាំងអោយកាន់មុខតំណែងណាមួយ ដែលមុខតំណែងថ្មីនេះទាបជាងក្របខ័ណ្ឌ ដោយបានគិតតាមសញ្ញាប័ត្រ ។

មាត្រា ៤.-

ការកំណត់ល័ក្ខខ័ណ្ឌប្រឡងប្រជែងផ្ទៃក្នុង ដើម្បីប្តូរក្របខ័ណ្ឌ ត្រូវកំណត់ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងស្ថាប័នពាក់ព័ន្ធ ។

មាត្រា ៥.-

ក្នុងករណីចាំបាច់ ដោយសារក្របខ័ណ្ឌ ឋានន្តរស័ក្តិមន្ត្រី ដែលត្រូវស្នើតែងតាំងនោះ មិនសមស្របនឹងតំណែងដែលត្រូវទទួល អាចត្រូវចាត់អោយមន្ត្រីនោះ បំពេញមុខងារក្នុងតំណែងនោះតែប៉ុណ្ណោះ ។ ករណីនេះ មន្ត្រីដែលទទួលបំពេញមុខងារមានសិទ្ធិទទួលប្រាក់បំណាច់ទាំងឡាយ ដែលមុខតំណែងនោះត្រូវបាន ហើយមន្ត្រីរូបនោះត្រូវបន្តការឡើងថ្នាក់ក្នុងក្របខ័ណ្ឌ និងឋានន្តរស័ក្តិរបស់ខ្លួន ដែលមានមុនការចាត់អោយបំពេញមុខងារថ្មីនេះ ។ ក្របខ័ណ្ឌ និងឋានន្តរស័ក្តិមិនត្រូវបានកែសំរួលតាមមុខតំណែងថ្មីនេះឡើយ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៧

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧២៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **អូហ្សាវ៉ៃណ** ជនជាតិជប៉ុន ជាប្រធានអង្គការ **JHP** ដែលបានផ្តល់អំណោយជាថវិកា ជួយកសាងអគារសិក្សា ចំនួន០២ខ្នង មាន០៧បន្ទប់ នៅអនុវិទ្យាល័យ ក្តុលដូនទាវ និង សាលាបឋមសិក្សាពោធិវង្ស បំពាក់ដោយគ្រឿងសង្ហារឹមគ្រប់គ្រាន់ ព្រមទាំងបង្គន់អនាម័យ ចំនួន០២ខ្នង មាន០៨បន្ទប់ ស្ថិតនៅឃុំចំការសំរោង និង ឃុំក្តុលដូនទាវ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៤៥.០០០ ដុល្លារអាមេរិក ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៦៧៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម SOTOSHU WOMEN 'S ASSOCIATION នៅប្រទេសជប៉ុន ដែលបានផ្តល់ជាថវិកាចំនួន ២៤.៣០០ ដុល្លារ សំរាប់ជួយកសាងអគារ សិក្សា ០១ ខ្នង មាន ០៥ បន្ទប់ បំពាក់សម្ភារៈគ្រប់គ្រាន់ រួមនឹង បង្គន់អនាម័យ ០៤ បន្ទប់ ជូនសាលាបឋមសិក្សាកោះរាំង ឃុំវត្តអង្គខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៩៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១គ្រឿង ជូនលោក **FUMIKO OSHIMA** ជនជាតិជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ចំនួន ០១ខ្នង មាន០៣បន្ទប់ បំពាក់ តុ កៅអីសិស្ស គ្រូ ក្តារខៀន ថាមពលពន្លឺព្រះអាទិត្យ ០៣បន្ទះ និង កុំព្យូទ័រ ០១គ្រឿង នៅសាលាបឋមសិក្សាគាប ឃុំទឹកថ្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់ ចំនួន ១៥.០០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៩០៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានប័ណ្ណពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៩ គ្រឿង ជូនសប្បុរសជនខ្មែរ រស់នៅសហរដ្ឋអាមេរិក ចំនួន ០៩ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងព្រះវិហារ វត្តពោធិបាក់កើតស្រះប៉ាំង ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

| | | | | | |
|---|---|---|---|---|---|
| ១-លោក | **ឡាច ភៅ** | និងអ្នកស្រី | **យី ត្ន** | ថវិកា | ៣៨.៨៩០ ដុល្លារ |
| ២-ឧបាសិកា | **តាន់ ណៃសុីន** | | | ថវិកា | ១០.០០០ ដុល្លារ |
| ៣-ឧបាសិកា | **យឹម យឿន** | | | ថវិកា | ១០.០០០ ដុល្លារ |
| ៤-លោក | **យ៉ាំ សំ** | និងអ្នកស្រី | **លឹម ង៉ែត** | ថវិកា | ១០.០០០ ដុល្លារ |
| ៥-លោក | **អ៊ុយ យឿន** | និងអ្នកស្រី | **ឈិន យ៉ាន់** | ថវិកា | ១០.០០០ ដុល្លារ |
| ៦-លោក | **នួល យា** | និងអ្នកស្រី | **នេត អ៊ាង** | ថវិកា | ១០.៧២០ ដុល្លារ |
| ៧-ឧបាសក | **ជិន អួយ** | និងឧបាសិកា | **ស្វាយ នេន** | ថវិកា | ១០.០០០ ដុល្លារ |
| ៨-ឧបាសិកា | **ឡុច ចឿត** | | | ថវិកា | ១០.០០០ ដុល្លារ |
| ៩-លោក | **យា ជិក** | និងអ្នកស្រី | **ហែម ភារា** | ថវិកា | ១០.០០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន និង ក្រុមហ៊ុន ដែលបានបរិច្ចាគធនធានជាថវិកា ចូលរួមចំណែកក្នុងការកសាងសមិទ្ធផលជាច្រើន លើវិស័យព្រះពុទ្ធសាសនា វិស័យអប់រំ វិស័យសង្គមកិច្ច និង គមនាគមន៍ នៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **សុខ គង់** អភិបាលស្រុកកំរៀង និង លោកស្រី **ញាន នារី**
ថវិកា ចំនួន ២១.៥០០ ដុល្លារ និង ៨៨៥.០០០ បាត

២-ក្រុមហ៊ុន **FRANASIE** ថវិកា ចំនួន ៥៩.០០០ ដុល្លារ និង ២.៥២៥.០០០ បាត

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧២៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានចំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣គ្រឿង ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងព្រះវិហារ វត្តអូរអណ្តូង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក **លី ហេង** និង អ្នកស្រី **សាង ចាន់ថ** | ថវិកា ចំនួន ១០.៤០០ ដុល្លារ |
| ២-លោក **ស សុធី** | ថវិកា ចំនួន ១០.៧០០ ដុល្លារ |
| ៣-លោកស្រី **ហែម សឿន** | ថវិកា ចំនួន ១០.៣០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៦២...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

### ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឡុច គា** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងអគារសិក្សា ចំនួន ០២ខ្នង និង ព្រះវិហារ នៅក្នុងវត្តអង់ពាង និង វត្តអង់ពាំពូង ស្រុកបន្ទាយមាស ខេត្តកំពត ចំណាយអស់ទឹកប្រាក់ ចំនួន ២២.០០០ ដុល្លារអាមេរិក ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥២៦ អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១គ្រឿង ប្រគេនព្រះតេជគុណ **នូ ផន** ព្រះចៅអធិការវត្តទន្លេបាទី ដែលបានបរិច្ចាគបច្ច័យចូលរួមចំណែកក្នុងការកសាងព្រះវិហារ កុដិ សាលាធម្មសភា របង ពុទ្ធមណ្ឌល និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងវត្តទន្លេបាទី ស្រុកបាទី ខេត្តតាកែវ ចំណាយអស់បច្ច័យ សរុបចំនួន ១០.២៥៣ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៧៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

### ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងសមិទ្ធផលជាច្រើន នៅក្នុងវត្តអង្គខ្ចាយ ឃុំដានគោម ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

១-លោកជំទាវឧកញ៉ា គូ **គីមឡុច** ថវិកា ១៨.៣៥០ ដុល្លារ

២-លោកជំទាវ **អ៊ុក ម៉ាលី** ភរិយា ឯកឧត្តម **ម៉ា ឈឿន** ថវិកា ១៦.២០០ ដុល្លារ

៣-ឯកឧត្តម **ម៉ៅ សុផាន់** ថវិកា ១៤.៦០០ ដុល្លារ

៤-លោកស្រី **អ៊ុក សាផន** ថវិកា ១២.៧០០ ដុល្លារ

៥-លោកស្រី **អ៊ុក ដារ៉ា** ថវិកា ១២.៨០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពត ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

៧០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ......អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
